## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍ស្តីអំពីការបណ្តុះបណ្តាលបំប៉ន
# ការងារគ្រប់គ្រងទិន្នន័យជំងឺអេដស៍ សំរាប់ថ្នាក់ខេត្ត-ក្រុង
(Refresher Training on Data Management System)
## នៅសណ្ឋាគារសៀមរាបថោន ខេត្ត សៀមរាប
## ថ្ងៃទី ០៣-០៥ ខែ ធ្នូ ឆ្នាំ ២០១៣

វគ្គបណ្តុះបណ្តាលបំប៉នស្តីអំពីការងារគ្រប់គ្រងទិន្នន័យអ្នកជំងឺអេដស៍ ថ្នាក់ខេត្ត-ក្រុងបានប្រព្រឹត្តទៅនៅ សណ្ឋាគារសៀមរាបថោន ខេត្តសៀមរាប ពីថ្ងៃទី ០៣ ដល់ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១៣, ដែលរៀបចំឡើងដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និងទទួលបាននូវការឧបត្ថម្ភថវិកាពីមូលនិធិសកល (Global Fund) ។ គោលបំណងនៃវគ្គបណ្តុះបណ្តាលនេះ គឺដើម្បីបង្ហាញអំពីប្រព័ន្ធគ្រប់គ្រងទិន្នន័យ សំរាប់ការយកទៅអនុវត្តនៅតាមគ្រប់ខេត្ត-ក្រុងទាំងអស់ ជាពិសេសផ្លាស់ប្តូរបទពិសោធន៏គ្នាទៅវិញទៅមករវាងមន្រ្តីទទួលបន្ទុកការងារគ្រប់គ្រងទិន្នន័យ-មន្រ្តីបញ្ចូលទិន្នន័យ និងមន្រ្តីទទួលបន្ទុកការងារគ្រប់គ្រងទិន្នន័យការឆ្លើយតបរួមគ្នា មានជាអាទិ៍ ការងារកត់ត្រាពតិមានរបស់អ្នកជំងឺអេដស៍-ការបញ្ចូលទិន្នន័យអ្នកជំងឺ និងការងារធ្វើរបាយការណ៏អំពីជំងឺអេដស៍ដែលបានអនុវត្តកន្លងមកនៅតាមបណ្តាខេត្ត-ក្រុងទាំងអស់ ។




**គ្រូសំរបសំរួលវគ្គ :**

លោក ម៉ម សុវត្ថា អនុប្រធានមជ្ឈមណ្ឌលជាតិ

លោកគ្រូពេទ្យ ជា ចំណាន អនុប្រធានផ្នែកគ្រប់គ្រងទិន្នន័យមជ្ឈមណ្ឌលជាតិ

លោកគ្រូពេទ្យ អឿន សារ៉ែម មន្ត្រីកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ និងកាមរោគ ខេត្តសៀមរាប និងមន្ត្រីផ្នែកគ្រប់គ្រងទិន្នន័យរបស់មជ្ឈមណ្ឌលជាតិ

**<u>សកម្មភាពនៃវគ្គបណ្តុះបណ្តាល</u> :**

ចាប់ពីម៉ោង ៧:៣០នាទី ដល់ ម៉ោង ៨:០០ : ការចុះឈ្មោះសិក្ខាកាមដែលមកចូលរួមទាំងអស់ ដែលក្នុងនោះមាន :

- មកពីខេត្ត បន្ទាយមានជ័យ ចំនួន ០៨ នាក់
- មកពីខេត្ត បាត់ដំបង ចំនួន ១០ នាក់
- មកពីខេត្ត កំពង់ចាម ចំនួន ០៩ នាក់
- មកពីខេត្ត កណ្តាល ចំនួន ០៦ នាក់
- មកពីខេត្ត កោះកុង ចំនួន ០៤ នាក់
- មកពីខេត្ត ពោធិ៍សាត់ ចំនួន ០៥ នាក់
- មកពីខេត្ត ស្វាយរៀង ចំនួន ០៤ នាក់
- មកពីខេត្ត ព្រៃវែង ចំនួន ០៦ នាក់
- មកពីខេត្ត សៀមរាប ចំនួន ០៨ នាក់
- មកពីខេត្ត ព្រះសីហនុ ចំនួន ០៣ នាក់
- មកពីខេត្ត តាកែវ ចំនួន ០៨ នាក់
- មកពីខេត្ត ឧត្តរមានជ័យ ចំនួន ០៣ នាក់
- មកពីខេត្ត កំពង់ស្ពឺ ចំនួន ០៥ នាក់
- មកពីខេត្ត កំពង់ឆ្នាំង ចំនួន ០៣ នាក់
- មកពីខេត្ត កំពង់ធំ ចំនួន ០៤ នាក់
- មកពីខេត្ត កំពត ចំនួន ០៣ នាក់
- មកពីខេត្ត ក្រចេះ ចំនួន ០៣ នាក់
- មកពីខេត្ត ស្ទឹងត្រែង ចំនួន ០៣ នាក់
- មកពីខេត្ត ប៉ៃលិន ចំនួន ០៣ នាក់
- មកពីខេត្ត ព្រះវិហារ ចំនួន ០៣ នាក់
- មន្ត្រីបញ្ចូលទិន្នន័យតាមមន្ទីរពេទ្យនានាក្នុងរាជធានីភ្នំពេញ ចំនួន ០៨ នាក់
- មកពីមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ចំនួន ២៨ នាក់

បន្ទាប់ពីការចុះឈ្មោះសិក្ខាកាមដែលមកចូលរួមរួចមក នៅវេលាម៉ោង៨:០០ វគ្គបណ្តុះបណ្តាលបានចាប់ផ្តើមដំណើរការរបស់ខ្លួន ដោយមានការចូលរួមជាគណៈអធិបតីក្នុងពិធីបើកវគ្គបណ្តុះបណ្តាលនោះមាន លោកវេជ្ជបណ្ឌិត លី ពេញស៊ុន អនុប្រធានមជ្ឈមណ្ឌលជាតិ និង លោកវេជ្ជបណ្ឌិត ក្រូស សារ៉ាត់ នាយកមន្ទីរសុខាភិបាលខេត្តសៀមរាប។ ក្នុងពិធីបើកវគ្គបណ្តុះបណ្តាលនោះ លោកវេជ្ជបណ្ឌិត ក្រូស សារ៉ាត់ នាយកមន្ទីរសុខាភិបាលខេត្តសៀមរាប បានមានមតិសំណេះសំណាលជាមួយសិក្ខាកាមយ៉ាងស្និតស្នាលបំផុត ដោយបានបង្ហាញពីសកម្មភាពនានាដែលទាក់ទងទៅនិងការអភិវឌ្ឍន៍វិស័យសុខាភិ

បាលរបស់ខេត្តសៀមរាប និងបានលើកនូវបទពិសោធន៏មួយចំនួនដែលទាក់ទងទៅនិងការប្រមូលរបាយការណ៏ របស់ខេត្តបញ្ជូនទៅកាន់ថ្នាក់ជាតិ និងរកវិធីសាស្ត្រយ៉ាងណាដើម្បីអោយ របាយការណ៏ដែលប្រមូលបាននោះមានភាពត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយ ដែលអាចយកជាការណ៏បាន ហើយលោកនាយកក៏បានផ្តាំផ្ញើ ដល់សិក្ខាកាមទាំងអស់អោយយកចិត្តទុកដាក់ក្នុងការសិក្សានេះ អោយទទួលបានជោគជ័យ និងការស្នាក់នៅប្រកបដោយសុវត្ថិភាព។ បន្ទាប់មកលោកវេជ្ជបណ្ឌិត លី ពេញស៊ុន អនុប្រធានមជ្ឈមណ្ឌលជាតិ, បានថ្លែងអំណរគុណដល់សិក្ខាកាមទាំងអស់ដែលបានធ្វើដំណើរមកចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ ដើម្បីទទួលយកនូវពតិមានថ្មីៗ និងធ្វើការផ្លាស់ប្តូរបទពិសោធន៏គ្នាទៅវិញទៅមកលើការងារកត់ត្រាពតិមានរបស់អ្នកជំងឺអេដស៏-ការបញ្ចូលទិន្នន័យអ្នកជំងឺ និងការងារធ្វើរបាយការណ៏អំពីជំងឺអេដស៏ដែលបានអនុវត្តកន្លងមកនៅតាមបណ្តាខេត្ត-ក្រុងទាំងអស់ និងការងារដែលបានអនុវត្តកន្លងមក ជាពិសេសដល់ការខិតខំប្រឹងប្រែងរួមគ្នាក្នុងការពិនិត្យ និងគ្រប់គ្រងទិន្នន័យអ្នកជំងឺឱកាសនិយម និងអ្នកជំងឺដែលប្រើប្រាស់ឱសថប្រឆាំងមេរោគអេដស៏ ធ្វើយ៉ាងណាជំរុញការអនុវត្តន៏នេះអោយកាន់តែមានប្រសិទ្ធភាពនៅគ្រប់ទីកន្លែង។



បន្ទាប់ពីការប្រកាសបើកវគ្គបណ្តុះបណ្តាលពីសំណាក់លោកវេជ្ជ. លី ពេញស៊ុន រួចមក វគ្គបណ្តុះបណ្តាលទាំងមូលបានចាប់ផ្តើមដំណើរការការងាររបស់ខ្លួន តាមកម្មវិធី និងពេលវេលាកំណត់ ដោយបានចាប់ផ្តើមធ្វើការបង្ហាញពីលទ្ធផលនានា ដែលបានអនុវត្តកន្លងមក និងទិសដៅការងារដែលត្រូវអនុវត្តបន្តលើការងារថែទាំ និងព្យាបាលជំងឺអេដស៏ ។





**ថ្ងៃទី ១** :

មុនពេលចាប់ផ្តើមដំណើរការកម្មវិធី ក្រុមការងារបានធ្វើការការបង្ហាញ-ណែនាំ និង រំលឹកឡើងវិញនូវគោលការណ៍ថ្នាក់ជាតិ៖

- ការបង្ហាញអំពីសកម្មភាពការងាររបស់ផ្នែកគ្រប់គ្រងទិន្នន័យក្នុងឆ្នាំ ២០១៣ និងទិសដៅសំរាប់អនុវត្តបន្តនៅឆ្នាំ ២០១៤ និង ឆ្នាំ ២០១៥
- ការបង្ហាញអំពីសកម្មភាពឆ្លើយតបរួមគ្នា (Linked Responde)

- ការបង្ហាញអំពីប្រព័ន្ធគ្រប់គ្រងទិន្នន័យ STD
- ការបង្ហាញអំពីប្រព័ន្ធគ្រប់គ្រងទិន្នន័យ VCCT-HTC
- ការបង្ហាញអំពីប្រព័ន្ធគ្រប់គ្រងទិន្នន័យកុមារប្រឈមនឹងមេរោគអេដស៍ (Exposed Infant)
- ការបង្ហាញអំពីប្រព័ន្ធគ្រប់គ្រងទិន្នន័យ OI/ART for Adult and Children
- ការបង្ហាញអំពីការអនុវត្តន៏ការងារ 3Is
- ការបង្ហាញអំពីការអនុវត្តន៏ការងារ Positive Prevention

និងមានការពិភាក្សាជារួមលើការងារប្រមូលរបាយការណ៍-ការរៀបចំរបាយការណ៍-ការបង្កើតរបាយការណ៏គ្រប់ជ្រុងជ្រោយ ជាពិសេសលើការផ្ញើរបាយការណ៏មកថ្នាក់ជាតិអោយបានទាន់ពេលវេលាកំណត់ ។



**ថ្ងៃទី ២** :

បន្ទាប់ពីការរំលឹកឡើងវិញអំពីសកម្មភាពការងារក្នុងថ្ងៃទីមួយរួចមក ក្រុមការងារបានបង្ហាញ-ណែនាំ និងរំលឹកឡើងវិញនូវគោលការណ៏ថ្នាក់ជាតិៈ

- ការបង្ហាញអំពីការអនុវត្តន៏ការងារ BCC
- ការបង្ហាញអំពីការអនុវត្តន៏ការងារ CBPCs
- ការបង្ហាញអំពីលទ្ធផលមន្ទីរពិសោធន៏ ពាក់ព័ន្ធលើការធ្វើតេស្ត CD4- Viral Load
- ការបង្ហាញអំពីការត្រៀមអនុវត្តការងារ Unique Identifier System (UIS) នៅក្នុងឆ្នាំ ២០១៤-២០១៥ សំរាប់ខេត្ត-ក្រុង ក្នុងទូទាំងប្រទេស
- ការបង្ហាញអំពីការអនុវត្តការងារកន្លងមកលើការងារ Continuum Quality Improvement (CQI) នៅតាមមន្ទីរពេទ្យនានា។
- បែងចែកជាក្រុម ដើម្បីធ្វើការពិភាក្សាលើការងារគ្រប់គ្រងទិន្នន័យ-លើប្រព័ន្ធគ្រប់គ្រងទិន្នន័យ (Database) -វិធីសាស្រ្តសំរាប់អនុវត្តលើការងារគ្រប់គ្រងទិន្នន័យជាបន្តទៀត។


DBS for DNA PCR
(Antibody Test)
Infant Test



















**ថ្ងៃទី ៣ :**

បន្ទាប់ពីការរំលឹកឡើងវិញអំពីសកម្មភាពការងារក្នុងថ្ងៃទីពីររួចមក ក្រុមការងារបានបង្ហាញ-ណែនាំអំពីៈ

- ការរៀបចំ Comprehensive provincial HIV/AIDS progress report ដែលជារបាយការណ៍គ្រប់ជ្រុងជ្រោយមួយដ៏មានសារៈសំខាន់ សំរាប់ធ្វើការវិភាគទៅលើទិន្នន័យដែលខេត្តនិមួយៗបានអនុវត្ត ។
- ការរៀបចំលើការងារវាយតំលៃបុគ្គលិកសំរាប់បន្តកិច្ចសន្យា និងការរៀបចំឯកសារប្រាក់បៀវត្សសំរាប់មន្ត្រីជាប់កិច្ចសន្យា មានជាអាទិ៍: ការរៀបចំ timesheet និង Leave record ។



__បញ្ហាដែលជួបប្រទះចំពោះការងារបញ្ចូលទិន្នន័យ__

- ការចុះបញ្ជី OI/ART មិនបានត្រឹមត្រូវ (លេខកូដជាន់គ្នា)- ការបំពេញទំរង់ពតិមានរបស់អ្នកជំងឺមិនទាន់បានគ្រប់គ្រាន់ និងខ្វះខាត ដូចជា កំពស់, ថ្ងៃណាត់ជួប, បរិមាណថ្នាំ, កំរិតថ្នាំ ធ្វើអោយការបញ្ចូលទិន្នន័យមានភាពមិនគ្រប់គ្រាន់តាមនោះដែរ- ករណីបញ្ជូនចេញ រឺ បញ្ជូនចូល (ពតិមានដែលត្រូវបំពេញមិនបានគ្រប់គ្រាន់) ។
- មានភាពខុសគ្នារវាងការបង្កើតរបាយការណ៍ដោយដៃ និងរបាយការណ៍អេឡិចត្រូនិកដោយប្រព័ន្ធកុំព្យូទ័រ ។
- ការបញ្ជូនរបាយការណ៍ពីកន្លែងសេវាផ្សេងៗមានការយឺតយ៉ាវ នាំអោយរបាយការណ៍ដែលត្រូវផ្ញើទៅកាន់មជ្ឈមណ្ឌលជាតិមានការយឺតយ៉ាវដែរ ។
- នៅខេត្តខ្លះមានកុមារដែលទទួល OI/ART មានអាយុលើសពី ១៤ឆ្នាំ ប៉ុន្តែមិនទាន់ញូនទៅកាន់សេវាមនុស្សពេញវ័យ ធ្វើអោយការបញ្ចូលពតិមានរបស់អ្នកជំងឺទៅក្នុង OI/ART Database មិនបានត្រឹមត្រូវ ។

__សេចក្តីសន្និដ្ឋាន__

បន្ទាប់ពីបានទទួលការសិក្សារយៈពេល ៣ថ្ងៃកន្លងមក ឃើញថាមន្ត្រីគ្រប់គ្រងទិន្នន័យថ្នាក់ខេត្ត-ក្រុង និងមន្ត្រីបញ្ចូលទិន្នន័យទាំងអស់ បានយល់ដឹងបន្ថែមលើការងារថ្មីមួយចំនួនដែលមជ្ឈមណ្ឌលជាតិ បាន និងកំពុងរៀបចំដាក់អោយប្រើប្រាស់មានជាអាទិ៍ : ការងារ Linked Response, Three I’s, Positive Prevention, HTC, CBPCs, BCC តាមរយៈការបង្ហាញរបស់គ្រូសម្របសម្រួលមកពីមជ្ឈមណ្ឌលជាតិ និងការយកចិត្តទុកដាក់របស់សិក្ខាកាមដែលអាចជួយបង្កើននូវចំណេះ

ដឹងរបស់មន្ត្រីគ្រប់គ្រងទិន្នន័យថ្នាក់ខេត្ត-ក្រុង មន្ត្រីបញ្ចូលទិន្នន័យ ក្នុងការប្រមូល, ពិនិត្យ និងធ្វើអោយ របាយការណ៍កាន់តែមានភាពសុក្រិតថែមទៀត មុននិងផ្ញើមកកាន់មជ្ឈមណ្ឌលជាតិ ។

ចំពោះការធ្វើតេស្តមុនវគ្គសិក្សាចំនួនភាគរយដែលសិក្ខាកាមអាចឆ្លើយសំនួរបានត្រឹមត្រូវមាន ៧៨ ភាគរយ ប៉ុន្តែបន្ទាប់ពីបានឆ្លងកាត់វគ្គបណ្តុះបណ្តាលនេះមកឃើញថាសមត្ថភាពរបស់សិក្ខាកាមអាចឆ្លើយសំនួរត្រឹមត្រូវបានច្រើនជាង ៩៥ ភាគរយ នេះអាចបញ្ជាក់អោយកាន់តែច្បាស់ថា វគ្គបណ្តុះបណ្តាលនេះពិតជាមានប្រយោជន៍ដល់សិក្ខាកាម ដែលជាមន្ត្រីគ្រប់គ្រងទិន្នន័យថ្នាក់ខេត្ត-ក្រុង និងមន្ត្រីបញ្ចូលទិន្នន័យពិតប្រាកដមែន ។

**<u>សំណូមពរ</u>**

- មានការបណ្តុះបណ្តាល រឺ ទស្សនៈកិច្ចសិក្សានៅតាមបណ្តាខេត្តផ្សេងៗ ដើម្បីផ្លាស់ប្តូរបទពិសោធន៏គ្នាទៅវិញទៅមក និងអភិបាលការងារនៅបណ្តាខេត្តដែលខ្លួនធ្វើការ
- សូមមេត្តាជួយរៀបចំការបើកប្រាក់បៀវត្សអោយបានយ៉ាងយូរនៅសប្តាហ៍ទី ១ នៃខែបន្ទាប់
- សូមអោយក្រុមការងារគ្រប់គ្រងទិន្នន័យ បានចូលរួមក្នុងកិច្ចប្រជុំគ្រប់ការងារណាដែលទាក់ទងនិង CoC ដើម្បីស្វែងយល់អំពីការងារ HIV/AIDS នឹងបានផ្តល់យោបល់លើការងារគ្រប់គ្រងទិន្នន័យ

**<u>ការសន្និដ្ឋានរួមៈ</u>**

នៅមុនពេលចាប់ផ្តើមនិងបញ្ចប់កម្មវិធី ក្រុមការងារបានធ្វើការពិនិត្យ នឹងវាយតំលៃវគ្គបណ្តុះបណ្តាល ហើយទទួលវគ្គបណ្តុះបណ្តាលបំប៉ននេះ បានបញ្ចប់នៅវេលាម៉ោង ១៧:៣០ ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១៣ ដោយមានការចូលរួមក្នុងការប្រកាសបិទវគ្គបណ្តុះបណ្តាលនេះដោយលោកវេជ្ជបណ្ឌិត គ្រួស សារ៉ាត់ នាយកមន្ទីរសុខាភិបាលខេត្តសៀមរាប ក្រោមបរិយាកាសរីករាយ និងស្និតស្នាលជាទីបំផុត ។

ធ្វើនៅភ្នំពេញ ថ្ងៃទី 12 ខែ ធ្នូ ឆ្នាំ ២០១៣

បានឃើញ និង ឯកភាព

វេជ្ជ.លី_ពេញ ស៊ុន

បានពិនិត្យ

ផ្ទ. ប្រធានផ្នែកគ្រប់គ្រងទិន្នន័យ

អ្នកធ្វើរបាយការណ៍

ផាត់ វ៉ាសនា